FIRST 5 CALIFORNIA

អាយុ ១ ឆ្នាំ ទៅ ២ ឆ្នាំ

ការរៀនសូត្រ ចាប់ផ្តើមតាំងពីក្មេងវ័យ

សង្ឃឹមចង់បានអ្វីខ្លះ
នៅពេលកូនក្មេងម្នាក់មានអាយុ ១ ទៅ ២ ឆ្នាំ
និងរបៀបដែលអ្នកអាចជួយក្មេងម្នាក់ឲ្យធំធាត់
និងរៀនសូត្រ

ក្មេងៗមាន កំឡាំងច្រើន ។ ក្មេងៗអាច :

- ដើរនឹងធ្លាក់ជ្រាន់លើ
- យកវត្ថុ១ចេញពីគ្នា
- រត់
- យួរឬបីវត្ថុ១
- រុញឬទ្រាន
- ឡើង
- ទាញឬអូស
- ចាប់យកវត្ថុ១

កូនរបស់អ្នកគឺរពឹស ហើយចូលចិត្ত :

- បិទបើក គន្ធីៈបិទបើកភ្លើង
- ណាបើកកញ្ចប់អ្វីមួយ
- ចាក់អ្វីចោល
- យកវត្ថុ១ចេញពីថតទូ ឬតុទូដាក់ចានក្បាន
- ចូលចិត្តធ្វើតំរាប់តាមសំឡេងអ្វីមួយ និងចូលចិត្តគ្រាប់តាមអ្នកផ្សេងៗទៀត ។

នៅរវាងខួបកំណើតឆ្នាំទីមួយ និងខួបកំណើត ឆ្នាំទីពីរ ក្មេងៗ :

- អាចពុតជាធ្វើការងារក្នុងផ្ទះ ឬធ្វើការនៅច្ចារក្រៅផ្ទះ ។
- ចង់ធ្វើអ្វីមួយដោយមិនពឹងផ្អែកគេ ។
- អាចថា "ទេ!" យ៉ាងច្រើន ។
- អាចមានស្មារតីពិត ។
- អាចសាកដើរថយក្រោយ ឬសាកដើរចំហៀងខ្លួន ។

ក្មេងៗក៏អាច :

- ចាប់ផ្តើមយើញ ថាតើគេមានលក្ខណៈដូចម្តេច ហើយមិនដូចនឹងក្មេងៗឯទៀតជាយ៉ាងណាទៅ ។
- សំគាល់អ្នកផ្សេង មានចិត្តជាយ៉ាងណា ។
- លេងតែម្នាក់ឯង ឬលេងជាមួយកូនក្មេងឯទៀតៗ ។
- យ្យនពាក្យបានច្រើន ។
- យល់ពីការអ្វីៗ ដែលមនុស្សថាស្តីឲ្យគេ បានច្រើន ។

នៅអាយុនេះ កូនក្មេងទាំងពួងត្រូវការមានឱ្យកាស ដើម្បី :

- រុករកកន្លែងលេងដែលមានក្តីសុខសាន្ត ។
- ធ្វើការសំរេចចិត្តដោយខ្លួនគេ ("តើឯងចង់បានពែងពណ៌ក្រហម ឬក៏ខ្សែ") ។
- រត់ ហក់ណោត និងលេង ។
- ប៉ះឬស្ទាប ភ្ជក់រសជាតិ ហិតក្លិន ស្តាប់សូរ និងមើលរបស់អ្វីៗដែលថ្មី ។
- រៀនពីការណាដែលបណ្តាលឲ្យមានលទ្ធផល (ដូចជានៅពេលគំនរក្រដាសរឹងជំរៀបជារូប មានកំពស់ខ្ពស់ពេក នោះវានឹងរលំដួល) ។
- យ្យន និងប្រើពាក្យថ្មីៗ ។
- យ្យនអំពីចិត្តសប្បុរស(ល្អ) និងការថ្នាក់ថ្នម ។

ល្បិច ដើម្បីចងចាំ : ផ្តល់សេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ដល់ក្មេងៗ ។

- អានសៀវភៅ ច្រៀងចំរៀង និងនិយាយជាមួយកូនៗ រៀងរាល់តែថ្ងៃ ។
- សំរបតាមសេចក្តីត្រូវការរបស់កូនៗ ដោយមិនយឺតយូរដ៏ធ្ងន់ ។
- កាន់ដៃកូនដ៏តូចរបស់អ្នក ឲ្យបានញ៉ីកញ្ជាប់ ។
- ធ្លើយសំដីកំសាន្ត និងសំណួរកូនរបស់អ្នក ។

ធ្វើឲ្យកន្លែងសំរាប់ក្មេងៗលេង ប្រកបដោយក្តីសុខសាន្ត ។

- ផ្តល់ពេលវេលាឲ្យកូនៗរត់ ហក់ណោត និងរាំរ៉ែក ។
- បណ្តាយកូនៗឲ្យគូរគំនូរ ឬលេងជាមួយដុំណើកតូចៗ និងបន្ទះក្រដាសរឹងៗ ជំរៀបជារូបផ្សេងៗ ។
- ផ្តល់ឱ្យកាសឲ្យកូនៗ ដើម្បីធ្វើការអ្វីមួយដោយខ្លួនឯង ។

វាក៏ជាការល្អផងដែរ ដើម្បី :

- ជ្រើសរើសពេលវេលា ដើម្បីលេងជាមួយក្មេងៗឯទៀត ។
- អនុញ្ញាតឲ្យកូនៗមានការជ្រើសរើសខ្លះ ។
- ត្រូវមានចិត្តសប្បុរស និងមានការថ្នាក់ថ្នម ធ្វើជាគំរូដល់កូនៗ ។

©2003 First 5 California

អាយុ ១ ឆ្នាំ ទៅ ២ ឆ្នាំ